**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Mar-2021, 15:02
CMS/CFO: Sann Rada

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សេចក្ដីសង្ខេបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកាលវិភាគដែលបានស្នើឡើងសម្រាប់សវនាការលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

| | |
|---|---|
| ជេត វណ្ណលី | Olivier BAHOUGNE |
| | Laure DESFORGES |
| ហុង គីមសួន | Ferdinand DJAMMEN NZEPA |
| គីម ម៉េងឃី | Isabelle DURAND |
| | Françoise GAUTRY |
| ឡោ ជុនធី | Emmanuel JACOMY |

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ម៉ុច សុវណ្ណារី
ស៊ិន ស៊ុវ៉ន
សំ សុគង់
វ៉ែន ពៅ
ទី ស្រ៊ីនណា

Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន

Anta GUISSÉ

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមដាក់សំណើសុំនេះ ដើម្បីជាការឆ្លើយតបទៅនឹងការអញ្ជើញ[1] របស់អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") ឱ្យដាក់សេចក្ដីសង្កេតលើកាលវិភាគដែលអង្គជំនុំជម្រះបានស្នើឡើងសម្រាប់សវនាការលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ("កាលវិភាគដែលបានស្នើឡើង")[2]។

2. ទីមួយ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា សំណើសុំនេះត្រូវបានកម្រិតដោយកត្តាពីរ។ អង្គជំនុំជម្រះពុំទាន់បានផ្ដល់បញ្ជីសំណួរជាក់លាក់មកឱ្យភាគី ដើម្បីលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់នៅឡើយទេ។ ទីពីរ ប្រធានបទដែលបានបញ្ជាក់ក្នុងកាលវិភាគដែលបានស្នើឡើងនោះ គឺមានលក្ខណៈទូទៅ និងបើកចំហឱ្យធ្វើការបកស្រាយ។

3. ទាក់ទងនឹងភាពគ្រប់គ្រាន់នៃពេលវេលាដែលបានបែងចែកនោះវិញ សហមេធាវីនាំមុខស្នើសុំឱ្យមានការកែប្រែតែមួយចំណុចទៅលើកាលវិភាគដែលបានស្នើឡើងនោះ។ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា នៅក្រោមចំណងជើងថា "ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលខៀវ សំផន ត្រូវបានសម្រេចថាមានទោស ("បទឧក្រិដ្ឋ") ភាគីត្រូវបានបែងចែកពេលវេលាចំនួន ៤៥ នាទីសម្រាប់ (មេធាវីការពារក្ដី) ៤០ នាទីសម្រាប់ (ការិយាល័យសហព្រះរាជអាជ្ញា) និង ៤០ នាទីសម្រាប់ (សហមេធាវីនាំមុខ)។ សហមេធាវីនាំមុខសូមស្នើថា បើធ្វើការពិចារណាពីចំនួនពេលវេលា និងភាពស្មុគស្មាញនៃទឡ្ហីករណ៍ពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងនោះ ការបែងចែកពេលវេលានេះគឺទំនងជាមិនគ្រប់គ្រាន់ឡើយ។ ចម្លើយតបរបស់សហមេធាវីនាំមុខមានកម្រាស់ប្រហែលជា ១៤៨ ទំព័រ (ស្មើនឹង ៤៨% នៃចំនួនទំព័រសរុប) ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ[3] ហើយត្រូវបានរំពឹងថា មេធាវីការពារក្ដីនឹងធ្វើការឆ្លើយតបយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើទឡ្ហីករណ៍ទាំងនោះដែលអាចតម្រូវឱ្យធ្វើការឆ្លើយតប។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខស្នើសុំ ដោយក្ដីគោរពឱ្យផ្ដល់ពេលវេលាបន្ថែមចំនួន ២០ នាទីទៀត ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងឡាយពាក់ព័ន្ធនឹង

---

[1] ឯកសារ **F60** ការអញ្ជើញដាក់សេចក្ដីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្ដឹងសារទុក្ខក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១។

[2] ឯកសារ **F60.1** ការអញ្ជើញភាគីឱ្យដាក់សេចក្ដីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្ដឹងសារទុក្ខក្នុងសំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ៖ កាលវិភាគសវនាការ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១។

[3] ឯកសារ **F54/2** ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ ទំព័រ ១៨២-៤១៥។

ប្រធានបទនេះ។

4. ជាចុងក្រោយ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា សំណើខាងលើនេះគឺផ្អែកទៅលើការយល់ឃើញថា ប្រធានបទស្តីពីបទឧក្រិដ្ឋនានា គឺរាប់បញ្ចូលទាំងនិយមន័យនៃបទឧក្រិដ្ឋទាំងនោះ (ធាតុផ្សំរបស់វា) និងនីត្យានុកូលភាពផងដែរ។ ដូចបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃសំណើសុំជាលាយលក្ខណ៍អក្សររបស់ខ្លួន សហមេធាវីនាំមុខពិចារណាឃើញថា បញ្ហាទាំងនេះជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយហេតុដូច្នេះ ត្រូវតែដោះស្រាយរួមគ្នាឱ្យបានសមស្របបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអង្គជំនុំជម្រះមានបំណងចង់យកបញ្ហានីត្យានុកូលភាពមកធ្វើការដោះស្រាយនៅក្រោមប្រធានបទ "ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ("យុត្តាធិការ") នោះ សហមេធាវីនាំមុខសំណូមពរថា ការបែងចែកពេលវេលាមកឱ្យសហមេធាវីនាំមុខគួរត្រូវបានកែប្រែដោយផ្តល់ពេលវេលាចំនួន ៤០ នាទី សម្រាប់បញ្ហាយុត្តាធិការ និង ៤០ នាទី សម្រាប់បញ្ហាបទឧក្រិដ្ឋទាំងឡាយនោះ។

5. បន្ថែមលើនេះទៀត ប្រសិនបើមេធាវីការពារក្តីស្នើសុំពេលវេលាបន្ថែមសម្រាប់ប្រធានបទណាមួយដែលត្រូវបានបែងចែកមកឱ្យសហមេធាវីនាំមុខហើយនោះ ហើយសំណើសុំនោះត្រូវបានអនុញ្ញាតនោះសហមេធាវីនាំមុខសំណូមពរថា ពេលវេលារបស់សហមេធាវីនាំមុខគួរត្រូវបានបន្ថែមតាមសមាមាត្រ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើង នៅក្នុងអំឡុងពេលនៃការផ្តល់ពេលវេលាបន្ថែមនេះ។

សូមដាក់ជូនដោយក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | រាជធានីភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខអន្តរជាតិ | រាជធានីភ្នំពេញ | |